**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.......................................................

## សុន្ទរកថា

## ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

## ថ្លែងក្នុងឱកាសបើកសិក្ខាសាលាស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

**នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៧**

សូមគោរព :

- **លោក Jean-Pierre Michau ទីប្រឹក្សាទេសាភិបាល ធនាគារកណ្តាលបារាំង**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី**

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយក្រៃលែង ដែលបានមកជួបជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញា ក្នុងសិក្ខាសាលាស្តីពី **ការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម** ដែលរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលបារាំង បន្ទាប់ពីប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ហើយក្នុងខណៈពេលដែលយើងកំពុងត្រៀមលក្ខណៈរៀបចំបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ (FIU) នៅពេលឆាប់ៗខាងមុខនេះ ។

លោក Jean-Pierre Michau អញ្ជើញមកដល់ប្រទេសកម្ពុជា ចំពេលដែលប្រជាជនកម្ពុជានៅទូទាំងប្រទេសកំពុងរៀបចំអបអរសាទរព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែ ដែលជាពិធីបុណ្យប្រពៃណីជាតិរបស់យើងតាំងពីបរមបុរាណ ។ ខ្ញុំសង្ឃឹមថា លោក Michau ពិតជាមានអារម្មណ៍សប្បាយរីករាយជាមួយនឹងការផ្លាស់ប្តូរបរិយាកាសនៅកម្ពុជា និងវប្បធម៌ប្រពៃណីជាតិខ្មែរ តាំងពីយូរលង់មក ។

ការរៀបចំសិក្ខាសាលារបស់យើងថ្ងៃនេះ គឺជាផ្នែកមួយនៃការអនុវត្តកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងធនាគារជាតិនៃកម្ពុជានិងធនាគារកណ្តាលបារាំង ដែលបានចុះហត្ថលេខារវាង ឯកឧត្តមទេសាភិបាល Christian Noyer កាលពីដើមឆ្នាំ២០០៦ ។ លោក Jean-Pierre Michau បានអញ្ជើញមកធនាគារជាតិនៃកម្ពុជា ចំនួនពីរលើកហើយ ។ នេះជាដំណើរទស្សនកិច្ចលើកទី២របស់លោក ដែលកាលពីលើកទី១ លោកបានអញ្ជើញមកប្រទេសកម្ពុជាឆ្លើយតបតាមការអញ្ជើញរបស់ធនាគារជាតិនៃកម្ពុជា នៅចុងឆ្នាំ២០០៤ ដើម្បីផ្តល់បទឧទ្ទេសនាមស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម បន្ទាប់ពីប្រទេសកម្ពុជា បានចូលជាសមាជិកពេញសិទ្ធិនៃ



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (APG) និងបានជួយផ្តល់យោបល់រៀបចំ និងកែលំអសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម របស់យើង ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះធនាគារកណ្តាលបារាំង ដែលតែងផ្តល់កិច្ចគាំទ្រ និងផ្តល់ជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា ជាពិសេស សូមថ្លែងអំណរគុណ និងសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះលោក Jean-Pierre Michau ទីប្រឹក្សាទេសាភិបាល ធនាគារកណ្តាលបារាំង ដែលបានចំណាយពេលវេលាដ៏មានតម្លៃ អញ្ជើញមកធនាគារជាតិនៃកម្ពុជា ដើម្បីចែករំលែកនូវបទពិសោធន៍ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ក្នុងខណៈដែលប្រទេសកម្ពុជា កំពុងចូលរួមជាមួយប្រទេសក្នុងតំបន់ និងពិភពលោក ដើម្បីប្រយុទ្ធប្រឆាំង នឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី**

ការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម គឺជាប្រធានបទមួយដ៏ក្តៅគគុក និងយ៉ាងសំខាន់ ដែលប្រទេសនៅក្នុងតំបន់ និងពិភពលោក កំពុងយកចិត្តទុកដាក់ការពារ ទប់ស្កាត់ និងលុបបំបាត់ ដោយសារស្ថានភាពបច្ចុប្បន្ននៃអំពើភេរវកម្មអន្តរជាតិដែលកំពុងរីករាលដាល និងគំរាមកំហែងដល់សុវត្ថិភាពប្រជាជន ស្ថិរភាពសង្គម និងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ តំបន់ និងពិភពលោក ហើយទំហំនៃការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធជារូបវ័ន្ត មានលក្ខណៈធ្ងន់ធ្ងរ មានអង្គការចាត់តាំងជាខ្សែចង្វាក់ឆ្លងដែន ជាពិសេស មានការគាំទ្រផ្នែកហិរញ្ញវត្ថុមកពីប្រភពផ្សេងៗ ។

ជារឿយៗ អ្នកសំអាតប្រាក់ បានប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុ ដែលជាស្នូលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសំរាប់សំអាតប្រាក់របស់ខ្លួន ។ ចំណែកឯ ពួកភេរវករវិញ ក៏បានប្រើប្រាស់ស្ថាប័នទាំងនេះដែរ ក្នុងបំណងដើម្បីយកទៅធ្វើវិច្ឆេទកម្មផ្នែកនយោបាយ ធ្វើឱ្យប្រជាពលរដ្ឋស្លូតត្រង់ស្លាប់ និងបំផ្លេចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសមួយឱ្យខូចខាត ។ ដោយយល់ឃើញពីសភាពបែបនេះ ទើបនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៤ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសំរេចឱ្យប្រទេសកម្ពុជាចូលជាសមាជិកនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសំអាតប្រាក់ (APG) ដើម្បីចូលរួមជាមួយសហគមន៍អន្តរជាតិ ចាត់វិធានការទប់ស្កាត់នូវបទល្មើសសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលកំពុងកើតមានឡើងក្នុងតំបន់ និងពិភពលោក ។

កាលពីថ្ងៃទី២៦ ខែកុម្ភៈ ដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៧ កន្លងមក ក្រុមការងារវាយតម្លៃទៅវិញទៅមក (Mutual Evaluation) ដឹកនាំដោយធនាគារពិភពលោក បានមកបំពេញបេសកកម្មនៅប្រទេសកម្ពុជាដើម្បីធ្វើការវាយតម្លៃពីក្របខ័ណ្ឌច្បាប់ និងកិច្ចសហប្រតិបត្តិការរបស់ប្រទេសកម្ពុជា ជាមួយប្រទេសក្នុងតំបន់ ក្នុងការ

បង្កើតយន្តការទប់ស្កាត់ការប្រឆាំងការសំអាតប្រាក់ តាមអនុសាសន៍ ៤០ និងអនុសាសន៍ពិសេស ៩ ទាក់ទងនឹងការប្រឆាំងហិរញ្ញប្បទានភេរវកម្ម ។ បន្ទាប់មកនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដើម្បីបង្ហាញពីឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការចូលរួមទប់ស្កាត់អំពើសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ជាមួយសហគមន៍អន្តរជាតិ ។

ដើម្បីអនុវត្តច្បាប់នេះទៅបាន តម្រូវឱ្យយើងបង្កើតក្រុមប្រឹក្សាភិបាលមួយដែលមានសមាសភាពមកពីក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី និងធនាគារជាតិនៃកម្ពុជា ហើយបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ (FIU) មួយ ដែលមានលេខាធិការដ្ឋាននៅធនាគារជាតិនៃកម្ពុជា ។ ដូច្នេះ បញ្ហាចំពោះមុខរបស់យើង គឺត្រូវបង្កើត និងដំណើការអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុមួយ និងការងារដែលត្រូវធ្វើបន្ទាប់ គឺអនុវត្តច្បាប់នេះឱ្យប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី**

ដោយសារការងារនេះ ជាការងារថ្មីសំរាប់កម្ពុជា ជាពិសេស ថ្មីសំរាប់មន្ត្រីប្រតិបត្តិរបស់កម្ពុជា គឺយើងចាប់ផ្តើមអនុវត្ត តាមគោលការណ៍ "**ធ្វើការងារបណ្តើរ រៀនសូត្របណ្តើរ និងដកស្រង់បទពិសោធន៍ពីប្រទេសជាមិត្តបណ្តើរ**" ហើយសិក្ខាសាលា ដែលលោក Jean-Pierre Michau នឹងធ្វើបទឧទ្ទេសនាមក្នុងរយៈពេលពីរថ្ងៃនេះ ពិតជាមានសារៈសំខាន់ ទាំងផ្នែកទ្រឹស្តី និងការអនុវត្តន៍ជាក់ស្តែង ចំពោះយើង ហើយជាពិសេស បានឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់យើងយ៉ាងពិតប្រាកដ ។

ខ្ញុំសង្ឃឹមថា លោក Michau នឹងជំរាបជូនពីបទពិសោធន៍ជាអន្តរជាតិ និងបរិបទនៃការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទាននៅកម្ពុជាជូនសិក្ខាកាមទាំងអស់គ្នាបានជ្រាប និងសូម លោក លោកស្រី ជាសិក្ខាកាមទាំងអស់ ខិតខំរៀនសូត្រ និងចូលរួមពិភាក្សា ដើម្បីបង្កបរិយាកាសឱ្យសិក្ខាសាលារបស់យើងកាន់តែមានភាពផុលផុស និងទទួលបានជោគជ័យ ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរឱ្យលោក Jean-Pierre Michau សូមស្នាក់នៅប្រទេសកម្ពុជាប្រកបទៅដោយក្តីសប្បាយរីករាយ ហើយឆ្លៀតឱកាសមុនថ្ងៃបុណ្យចូលឆ្នាំថ្មី២០០៨ ឆ្នាំសកល ខ្ញុំសូមជូនពរផងដែរ ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញាទាំងអស់ មានសុខភាពល្អ និងទទួលបានជ័យជំនះគ្រប់ភារកិច្ច ។

ខ្ញុំសូមប្រកាសបើកសិក្ខាសាលាស្តីពី "**ការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម**" ចាប់ពី ពេលនេះតទៅ ។

**សូមអរគុណ !**